ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

ខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនមេត្តាជ្រាបថា ក្នុងរយៈកាលពីរ-បីថ្ងៃកន្លងមកនេះ មានកាសែតក្នុងស្រុកមួយ បានចុះផ្សាយនូវអត្ថបទព័ត៌មានបំផ្លើសខុសពីការពិតដោយគ្មានមូលដ្ឋានច្បាស់លាស់ត្រឹមត្រូវ ចោទប្រកាន់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាន “ទិញរថយន្តទំនើបម៉ាក Rolls Royce តម្លៃជិត ១ លានដុល្លារអាមេរិក” ។

ខុទ្ទកាល័យសូមធ្វើការបដិសេធទាំងស្រុងចំពោះការផ្សព្វផ្សាយព័ត៌មាននោះ ដែលជាព័ត៌មានភូតកុហកបំផ្លើសការពិត មានចេតនាមូលបង្កាច់ និងបង្ខូចកិត្តិយស ដែលបានបំពានលើគោលការណ៍គ្រឹះជាសារវន្តនៃសេរីភាពក្នុងការបញ្ចេញមតិជាសាធារណៈ និងមិនគោរពក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ក៏ដូចជាច្បាប់ស្តីពីរបបសារព័ត៌មាន ។ ការចុះផ្សាយព័ត៌មានដោយគ្មានការទទួលខុសត្រូវ និងគ្មានមូលដ្ឋានបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយសរបស់ឯកឧត្តមរដ្ឋមន្ត្រី ក៏ដូចជាសេចក្តីថ្លៃថ្នូររបស់អ្នកសារព័ត៌មានដទៃទៀតដែលប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងវិជ្ជាជីវៈសារព័ត៌មាន ។

ខុទ្ទកាល័យសូមអំពាវនាវដល់សារព័ត៌មានពាក់ព័ន្ធ ប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មានក្នុងការផ្សព្វផ្សាយនូវព័ត៌មានដែលមានប្រភពពិតប្រាកដ ត្រឹមត្រូវ ដោយវិធីសុចរិត គតិយុត្តិធម៌ ដើម្បីរួមចំណែកលើកស្ទួយវិជ្ជាជីវៈសារព័ត៌មាន សេចក្តីថ្លៃថ្នូរ និងជាកញ្ចក់សច្ចធម៌ សម្រាប់ជាឧត្តមប្រយោជន៍ដល់ជាតិមាតុភូមិ និងប្រជាពលរដ្ឋកម្ពុជា ។

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ ២០១៤*

**ខុទ្ទកាល័យ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា ខុទ្ទកាល័យ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

St,92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.

www.mef.gov.kh

ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

Phone : 855-23-724 664 Fax : 855-23-427 798

mef_adm@yahoo.com